ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ៧០២-៤២០-៣៥២-ធ.ជ.ក

# សេចក្តីណែនាំ
## ស្តីពី
## ការកំណត់ចំនួនទឹកប្រាក់ក្នុងការអនុវត្តវិធានការ យកចិត្តទុកដាក់ស្គាល់អតិថិជនសម្រាប់កាស៊ីណូ និងគ្រឹះស្ថានល្បែងស៊ីសងផ្សេងៗ

អនុលោមតាមមាត្រា៨ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦២០/០២១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាដាក់ចេញនូវសេចក្តីណែនាំស្តីពីការកំណត់ចំនួនទឹកប្រាក់ក្នុងការអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន សម្រាប់កាស៊ីណូ និងគ្រឹះស្ថានល្បែងស៊ីសងផ្សេងៗ។

ចំនួនទឹកប្រាក់ក្នុងការអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន ឬអត្ថគាហក ដែលមានប្រតិបត្តិការជាមួយកាស៊ីណូ និងគ្រឹះស្ថានល្បែងស៊ីសងផ្សេងៗ ដូចមានចែងក្នុងកថាខណ្ឌ១៣ នៃមាត្រា២ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម មានដូចតទៅ៖

- នៅពេលអតិថិជន ឬអត្ថគាហកអនុវត្តប្រតិបត្តិការ ដែលមានទឹកប្រាក់ស្មើ ឬលើសពី ១២.០០០.០០០ (ដប់ពីរលាន) រៀល ឬសមមូលនឹងរូបិយប័ណ្ណផ្សេងទៀត
- ប្រតិបត្តិការនេះរួមមានប្រតិបត្តិការច្រើនដងរបស់អតិថិជន ឬអត្ថគាហកម្នាក់ដែលមានចំនួនសរុបនៃប្រតិបត្តិការរួមគ្នាក្នុងរយៈពេល ២៤ ម៉ោង ដែលមានចំនួនស្មើ ឬលើសពី ១២.០០០.០០០ (ដប់ពីរលាន) រៀល ឬសមមូលនឹងរូបិយប័ណ្ណផ្សេងទៀត។

កាស៊ីណូ និងគ្រឹះស្ថានល្បែងស៊ីសងផ្សេងៗ ទាំងឡាយណាដែលមិនអនុវត្តតាមសេចក្តីណែនាំនេះ ត្រូវផ្តន្ទាទោសដូចមានចែងនៅក្នុងមាត្រា៣៦ និងមាត្រា៣៧ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

ទទួលបានសេចក្តីណែនាំនេះ គ្រប់កាស៊ីណូ និងគ្រឹះស្ថានល្បែងស៊ីសងផ្សេងៗ ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ អង្គារ ១០រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០
**អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**
**ប្រធាន**

ស.ហ.ក

**សាយ សំអាត**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ធនាគារជាតិនៃកម្ពុជា
- គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- ក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- គ្រប់កាស៊ីណូ និងគ្រឹះស្ថានល្បែងស៊ីសងផ្សេងៗ
- ឯកសារ-កាលប្បវត្តិ